ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧១ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីដឹកនាំ សម្របសម្រួល និងជម្រុញការអនុវត្តគម្រោង ហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានថ្មី ខ្ពាតតំបន់ នៅខេត្តមណ្ឌលគិរី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- យោងតាមសំណើរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

## សម្រេច

**ប្រការ១.**_

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីដឹកនាំ សម្របសម្រួល និងជម្រុញការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានថ្មី ខ្ពាតតំបន់ នៅខេត្តមណ្ឌលគិរី សរសេរជាអក្សរកាត់ថា "**គ.ជ.ស.ជ**" ដែលបានស្នើសុំវិនិយោគដោយក្រុមហ៊ុន ផៅវ័រឆាយណា អ៊ីនធើនេសិនណល គ្រុប (Powerchina International Group/PIG) ក្រោមទម្រង់

សាងសង់-ធ្វើប្រតិបត្តិការ-ផ្ទេរ (Build-Operate-Transfer) ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ប្រធាន |
| ២- ឯកឧត្តម **ជា អួន** | រដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | អនុប្រធាន |
| ៣- ឯកឧត្តម **ផាន់ ផល្លា** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- ឯកឧត្តម **ជា បូរ៉ា** | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ៥- ឯកឧត្តម **ស៊ីន ចាន់សិរីវុត្ថា** | អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | **សមាជិកអចិន្ត្រៃយ៍** |
| ៦- ឯកឧត្តម **ហាង្ស សុតសំភារ** | អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៧- ឯកឧត្តម **គង់ ច័ន្ទឋាសនា** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨- ឯកឧត្តម **ស៊ឹម យ៉ារ៉ែន** | អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| ៩- ឯកឧត្តម **ជា ឧុត្ថិ** | អគ្គលេខាធិការរង គណៈកម្មាធិការវិនិយោគកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១០- ឯកឧត្តម **ស្វាយ សំអៀង** | អភិបាល នៃគណៈអភិបាលខេត្តមណ្ឌលគិរី | សមាជិក |
| ១១- ឯកឧត្តម **ខាន់ វណ្ណារា** | អគ្គនាយកបច្ចេកទេស រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១២- ឯកឧត្តម **សេខ សន្ធា** | អគ្គនាយករដ្ឋបាល និងកិច្ចការទូទៅ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១៣- លោក **ឱម ម៉ាក់ឆារិទ្ធ** | ប្រធានស្តីទី អង្គភាពជាដៃគូរវាងរដ្ឋ និងឯកជនថ្នាក់កណ្តាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ២.**_

**គ.ជ.ស.ជ** នេះ មានភារកិច្ចដូចតទៅ៖

- ដឹកនាំ និងចរចាលើការរៀបចំកិច្ចព្រមព្រៀងក្របខ័ណ្ឌ (Framework Agreement) ជាមួយក្រុមហ៊ុន ផៅវ័រឆាយណា អ៊ីនធើនេសិនណល គ្រុប (Powerchina International Group/PIG) ដើម្បីអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានថ្មី ខេត្តមណ្ឌលគិរី
- ដឹកនាំ ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់អនុសាសន៍ លើការសិក្សាទាំងឡាយដែលពាក់ព័ន្ធដល់គម្រោងហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានថ្មី ខេត្តមណ្ឌលគិរី ដោយសហការសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដឹកនាំ និងចរចាលើការរៀបចំកិច្ចសន្យាភាពជាដៃគូរវាងរដ្ឋ និងឯកជន (កិច្ចសន្យា ភ.រ.ឯ/PPP Contract) រហូតដល់ការចុះកិច្ចសន្យាជាស្ថាពរ
- ត្រួតពិនិត្យ វាយតម្លៃ ជម្រុញ និងតាមដានកាតព្វកិច្ច សមិទ្ធកម្ម និងវឌ្ឍនភាពនៃការអនុវត្តគម្រោងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានរបស់ក្រុមហ៊ុន ផៅវ័រឆាយណា អ៊ីនធើនេសិនណល គ្រុប (Powerchina International Group/PIG) និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តពាក់ព័ន្ធ រហូតគម្រោងនេះត្រូវបានបញ្ចប់ជាស្ថាពរ
- ពិនិត្យ វាយតម្លៃ និងសម្រេចដាក់ចេញអនុសាសន៍ណែនាំចាំបាច់នានា ដើម្បីដោះស្រាយបញ្ហាប្រឈម។ ក្នុងករណីមានវេទយិតភាព ត្រូវស្នើសុំគោលការណ៍សម្រេចពីរាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍ និងលើកយោបល់ជូនរាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជម្រុញដំណើរការអនុវត្តគម្រោងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានថ្មី ខេត្តមណ្ឌលគិរី។

**ប្រការ៣.**_

**គ.ជ.ស.ជ** នេះ មានក្រុមការងារភាពជាដៃគូរវាងរដ្ឋ និងឯកជន របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ជាសេនាធិការក្នុងការជួយសម្របសម្រួល និងគាំទ្រលើការងារបច្ចេកទេសក្នុងការអនុវត្តគម្រោងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានដោយក្រុមហ៊ុន ផៅវើឆាយណា អ៊ីនធើនេសិនណល គ្រុប (Powerchina International Group/PIG) និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តពាក់ព័ន្ធ ។

**ប្រការ៤.**_

អនុប្រធាន និងសមាជិក នៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ប្រធានគណៈកម្មការមានសិទ្ធអញ្ជើញតំណាងពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ឱ្យចូលរួមប្រជុំ ក្នុងករណីចាំបាច់។

គណៈកម្មការនេះ មានសិទ្ធប្រើប្រាស់ត្រារបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

**ប្រការ៥.**_

**គ.ជ.ស.ជ** នេះ មានសុពលភាពរហូតដល់គម្រោងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានថ្មី ខ្នាតតំបន់ នៅខេត្តមណ្ឌលគិរី ត្រូវបានបញ្ចប់ជាស្ថាពរ។

**ប្រការ៦.**_

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ព្រមទាំងសមាសភាពដែលមានចែងក្នុងសេចក្តីសម្រេចនេះ ត្រូវទទួលបន្ទុកអនុវត្តភារកិច្ចតាមសមត្ថកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ